00210155

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C 33/I/5

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៩)**

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 08 / 2008
ម៉ោង (Time/Heure): 14 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**កាលបរិច្ឆេទ:** ៧ សីហា ២០០៨

# សេចក្តីសម្រេចចំពោះការបញ្ជាក់លើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ដែលប្តឹងប្រឆាំងចំពោះលក្ខខណ្ឌនៃការឃុំខ្លួន ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**
នួន ជា

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky
យ៉ុង ផានិត

**សហមេធាវីការពារក្តី**
សុន អារុណ
Michiel PESTMAN
Victor KOPPE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 07 / 08 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (“**អវតក**”) កត់សម្គាល់ឃើញមាន“បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទដែលប្តឹងប្រឆាំងចំពោះដីកាស្តីពីលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន” ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៨ (“បណ្តឹងឧទ្ធរណ៍”)។

២. អនុលោមតាមវិធាន ៧៧(៣)នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះត្រូវធ្វើការកំណត់កាលបរិច្ឆេទសវនាការបន្ទាប់ពីទទួលបានបណ្តឹងឧទ្ធរណ៍ ឬពាក្យសុំ។[1]

៣. ប៉ុន្តែ អង្គបុរេជំនុំជម្រះសង្កេតឃើញថា នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៨ សហមេធាវីការពារក្តីរបស់ជនត្រូវចោទបានបង្ហាញការយល់ឃើញរបស់ខ្លួនក្នុងលក្ខណៈមិនផ្លូវការថា សវនាការដេញដោលមិនចាំបាច់ រៀបចំឡើយចំពោះករណីនេះ ហើយបណ្តឹងឧទ្ធរណ៍នេះអាចយកមកធ្វើការសម្រេច ដោយផ្អែកលើតែសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបាន។”

៤. នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានធ្វើការគូសបញ្ជាក់ក្នុងលក្ខណៈមិនផ្លូវការថាខ្លួននឹងរង់ចាំសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះចំពោះករណីនេះ។

៥. អង្គបុរេជំនុំជម្រះពិចារណាឃើញថា បញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ សមស្របនឹងយកមកធ្វើការសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។

៦. បន្ទាប់ពីធ្វើការពិចារណាអំពីការយល់ឃើញរបស់ជនត្រូវចោទ និងសហព្រះរាជអាជ្ញា (“ភាគី”) អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះអាចយកមកធ្វើការសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។

៦. អនុលោមតាមមាត្រា ៨(៤)នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក សំណើឆ្លើយតបចំពោះសារណា នឹងត្រូវអនុញ្ញាត ក្នុងករណីដែលមិនមានអំណះអំណាងដេញដោលដោយផ្ទាល់មាត់។[2]

[1] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (វិសោធនកម្មលើកទី ១) ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៨។

[2] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី២។

00210157



C33/I/5

## ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេច និងណែនាំ:

(១) បណ្តឹងឧទ្ធរណ៍នឹងធ្វើការសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានតបរបស់ភាគីតែប៉ុណ្ណោះ។

(២) អនុញ្ញាតឱ្យជនត្រូវចោទដាក់សេចក្តីសន្និដ្ឋានតបទៅនឹងសេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាក្នុងរយៈពេលប្រាំ(៥)ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចនេះ។ ៕

ភ្នំពេញ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គីមសាន**